## អ្នកអាចធ្វើកិច្ចសម្ភាសន៍របស់ អ្នកនៅការិយាល័យសេវាសហគមន៍ ក្នុងតំបន់របស់អ្នក ឬតាមទូរសព្ទ នៅលេខ **1-877-501-2233**



ដើម្បីដាក់ពាក្យសុំអាហារមូលដ្ឋានតាមអនឡាញ ចូលទៅកាន់៖

**washingtonconnection.org**

អ្នកអាចធ្វើកិច្ចសម្ភាសន៍របស់អ្នកនៅការិយាល័យសេវាសហគមន៍ក្នុង តំបន់របស់អ្នក ឬតាមទូរសព្ទនៅលេខ៖

**1-877-501-2233**

សម្រាប់ព័ត៌មានបន្ថែមលើអាហារមូលដ្ឋាន និងការងារ និងកម្មវិធីបណ្តុះបណ្តាល ចូលតាម អនឡាញទៅកាន់៖

**www.dshs.wa.gov/esa/community-partnership-program/basic-food-employment-training-bfet**

Washington State Department of Social & Health Services

*Transforming lives*

DSHS 22-1572 CA (Rev. 6/18) Cambodian

# តើអ្នកគ្មានផ្ទះ សម្បែងមែនទេ?

## អាហារមូលដ្ឋាន អាចជួយបាន!



Take a Fresh Look

**Basic Food**

## តើខ្ញុំអាចទទួលអាហារមូលដ្ឋានប្រសិនបើខ្ញុំរស់នៅតាមដងផ្លូវ នៅក្នុងទីជម្រក នៅក្នុងរថយន្ត នៅក្នុងផ្ទះសំណាក់ ឬនៅក្នុងស្ថានភាពបណ្ដោះអាសន្នណាមួយឬទេ?

- ប្រសិនបើអ្នកមិនមានលំនៅដ្ឋានអចិន្ត្រៃយ៍ទេ អ្នកនៅតែអាចមានលក្ខណៈសម្បត្តិសម្រាប់អាហារមូលដ្ឋាន។ អ្នកអាចប្រើរបស់អ្នកតំណាងដែលមានការអនុញ្ញាតជាកន្លែងទទួលសំបុត្រ។
- ប្រសិនបើអ្នកកំពុងស្នាក់នៅទីជម្រក អ្នកនៅតែអាចទទួលអាហារមូលដ្ឋានបើទោះបីជាទីជម្រកផ្ដល់អាហារក៏ដោយ។
- ប្រសិនបើអ្នកអាយុក្រោម 18 ឆ្នាំ គ្មានផ្ទះសម្បែង ហើយមិនរស់នៅជាមួយឪពុកម្ដាយ ឬអាណាព្យាបាលរបស់អ្នកទេ អ្នកនៅតែអាចទទួលបានអាហារមូលដ្ឋាន។

## តើខ្ញុំអាចទទួលអាហារមូលដ្ឋានខណៈពេលខ្ញុំស្នាក់នៅជាមួយនរណាម្នាក់នៅក្នុងរយៈពេលខ្លីឬទេ?

អ្នកនៅតែអាចមានសិទ្ធិសម្រាប់អាហាមូលដ្ឋានបើទោះបីជាអ្នកកំពុងស្នាក់នៅជាមួយនរណាម្នាក់រហូតដល់ 90 ថ្ងៃ។

- ប្រសិនបើអ្នកគ្មានប្រាក់ ហើយបច្ចុប្បន្នបរិភោគជាមួយអ្នករួមផ្ទះរហូតដល់អ្នកអាចទទួលបានប្រាក់សម្រាប់ទិញអាហារ អ្នកមិនចាំបាច់ដាក់ពាក្យសុំជាមួយអ្នកដែលអ្នកកំពុងស្នាក់នៅជាមួយ លុះត្រាតែអ្នកមានគម្រោងទិញ និងចម្អិនម្ហូបជាប្រចាំជាមួយពួកគេបន្ទាប់ពីអ្នកទទួលបានអាហារមូលដ្ឋាន។
- ប្រសិនបើអ្នកទិញ និងចម្អិនម្ហូបជាប្រចាំជាមួយមនុស្សដែលអ្នកកំពុងស្នាក់នៅជាមួយ អ្នកទាំងអស់នឹងត្រូវដាក់ពាក្យសុំ និងមានសិទ្ធិសម្រាប់អាហារមូលដ្ឋានជាមួយគ្នា។
- ប្រសិនបើអ្នកទិញ និងចម្អិនម្ហូបជាប្រចាំសម្រាប់ខ្លួនឯង ឬគ្រួសាររបស់អ្នកតែប៉ុណ្ណោះ អ្នកមិនចាំបាច់ដាក់ពាក្យសុំជាមួយអ្នកដទៃដែលបច្ចុប្បន្នអ្នកកំពុងស្នាក់នៅជាមួយ លុះត្រាតែអ្នកមានអាយុក្រោម 22 ឆ្នាំ ហើយអ្នកកំពុងស្នាក់នៅជាមួយឪពុកម្ដាយរបស់អ្នក។

## តើខ្ញុំដាក់ពាក្យសុំអាហារមូលដ្ឋានដោយរបៀបណា?

អ្នកអាចដាក់ពាក្យសុំអាហារមូលដ្ឋានដោយ៖

- ទៅកាន់ការិយាល័យសេវាសហគមន៍ក្នុងតំបន់របស់អ្នក
- ដាក់ពាក្យសុំតាមអនឡាញនៅ៖ **washingtonconnection.org** ឬ
- ទទួលជំនួយដើម្បីដាក់ពាក្យពីអ្នកផ្ដល់សេវាចែកចាយអាហារមូលដ្ឋាន។
- DSHS ធ្វើការជាមួយដៃគូសហគមន៍ជាមួយច្រើនដើម្បីផ្ដល់កម្មវិធីអាហាមូលដ្ឋាន និងជួយជាមួយដំណើរការកម្មវិធី ចូលអនឡាញទៅកាន់៖ **washingtonconnection.org/home/publicaccessdirectory.go**

អ្នកអាចប្រើកុំព្យូទ័រនៅបណ្ណាល័យសាធារណៈភាគច្រើនដើម្បីចូលប្រើអ៊ីនធឺណិត។

## តើខ្ញុំត្រូវការរូបថត ID ឬភស្តុតាងបញ្ជាក់ថាខ្ញុំជានរណាដើម្បីដាក់ពាក្យសុំអាហារមូលដ្ឋាន

រូបថត ID គឺជាវិធីមួយដើម្បីបញ្ជាក់អត្តសញ្ញាណ។ អ្នកមិនអាចត្រូវបានបដិសេធសម្រាប់អត្ថប្រយោជន៍អាហាមូលដ្ឋានទេ ដោយសារអ្នកមិនមានរូបថត ID។ អ្នកអាចប្រើទម្រង់ផ្សេងនៃ ID ដូចជា៖

- ប័ណ្ណ ID កន្លែងធ្វើការ ឬសាលារៀន
- សំបុត្រកំណើត
- ប័ណ្ណចុះឈ្មោះបោះឆ្នោត
- ប័ណ្ណអត្ថប្រយោជន៍សុខភាព
- ID ពីសេវាសង្គមផ្សេងទៀត
- ចុងសន្លឹកប្រាក់ខែ

បុគ្គលិកអាហារមូលដ្ឋានអាចពិនិត្យអត្តសញ្ញាណរបស់អ្នកដោយទូរសព្ទទៅបុគ្គលិកទីជម្រក ឬនិយោជករបស់អ្នក។

## តើខ្ញុំត្រូវមានកិច្ចសម្ភាសន៍សម្រាប់អាហារមូលដ្ឋានឬទេ?

អ្នកត្រូវតែមានកិច្ចសម្ភាសន៍សម្រាប់អាហារមូលដ្ឋាន។ អ្នកអាចធ្វើកិច្ចសម្ភាសន៍របស់អ្នកនៅការិយាល័យសេវាសហគមន៍ក្នុងតំបន់របស់អ្នក ឬតាមទូរសព្ទនៅលេខ៖ **1-877-501-2233**.



## តើខ្ញុំអាចទទួលជំនួយជាមួយការបណ្ដុះបណ្ដាល ឬការស្វែងរកការងារឬទេ?

- មែន! ប្រសិនបើអ្នកទទួលបានជំនួយអាហារមូលដ្ឋាន អ្នកអាចស្ម័គ្រចិត្តសម្រាប់កម្មវិធីការងារ និងការបណ្ដុះបណ្ដាលអាហារមូលដ្ឋាន (BFET) ។
- BFET ផ្ដល់ការស្វែងរកការងារ ការបណ្ដុះបណ្ដាលការស្វែងរកការងារ សេវាអប់រំ ការបណ្ដុះបណ្ដាលជំនាញ និងឱកាសការងារផ្សេងទៀតដល់មនុស្សដែលទទួលអាហារមូលដ្ឋាន។

អង្គការជាច្រើនអាចផ្ដល់ជំនួយជាមួយការដឹកជញ្ជូន ការថែទាំកុមារ ឬធនធានផ្សេងទៀតដែលអាចជួយអ្នកធ្វើការឆ្ពោះទៅកាន់គោលដៅអាជីពរបស់អ្នក។ សេវាត្រូវបានផ្ដល់តាមរយៈសហគមន៍ ឬមហាវិទ្យាល័យបច្ចេកវិទ្យា និង/ឬសហគមន៍ផ្អែកលើអង្គការ (CBO) និងគ្របដណ្ដប់ភាពសម្បូរបែបនៃវិស័យការងារ និងវិស័យអាជីព។ សម្រាប់ព័ត៌មានបន្ថែមលើសេវា BFET ចូលអនឡាញទៅកាន់៖ **www.dshs.wa.gov/esa/community-partnership-program/basic-food-employment-training-bfet**